WaterSHED

Water, Sanitation & Hygiene Enterprise Development

# ស្ត្រីក្នុងវិស័យទីផ្សារផ្គត់ផ្គង់ទឹកស្អាត និង អនាម័យ

## ការធ្វើឲ្យប្រសើរឡើងនូវគោលដៅសម្រាប់កម្មវិធីនៅពេលអនាគត

២០២០






Water SHED
Water, Sanitation & Hygiene Enterprise Development

# សាវតា

# អង្គការវ៉តធើសេដ

**អង្គការវ៉តធើសេដ** ធ្វើការងារផ្តោតទៅលើការពង្រឹងប្រព័ន្ធថ្នាក់មូលដ្ឋាន ដោយបង្កើតទីផ្សារជនបទ សម្រាប់ផលិតផល និងសេវាកម្មអនាម័យ នៅខេត្តចំនួន៨ ក្នុងប្រទេសកម្ពុជា។




តួលេខ១. ខេត្តគោលដៅនៃគម្រោងរួមគ្នាធ្វើការ

# ការសិក្សាស្រាវជ្រាវជាផ្លូវការ (២០១៣)

ការវាយតម្លៃនៃការស្រាវជ្រាវរបស់**អង្គការវ៉តជើសេដ** អំពីការលើកកម្ពស់សេដ្ឋកិច្ចស្ត្រីនៅក្នុងទីផ្សារអនាម័យជនបទបានរកឃើញថា **យេនឌ័រ** ជាបញ្ហាប្រឈមមួយក្នុងការរារាំងស្ត្រីមិនឲ្យទទួលបានធនធានចាំបាច់ ដើម្បីចាប់ផ្តើម ឬពង្រីកអាជីវកម្មផ្គត់ផ្គង់បង្គន់អនាម័យ។



# គម្រោងរួមគ្នាធ្វើការ (២០១៦)

WaterSHED
Water, Sanitation & Hygiene Enterprise Development

**គម្រោងនេះ** គឺជាការបណ្តុះបណ្តាលជាស៊េរី លើមុខជំនាញផ្ទាល់ខ្លួន និងជំនាញវិជ្ជាជីវៈ ក៏ដូចជាមានការប្រឹក្សាទៅលើការ បង្កើតបណ្តាញដែលមានជំនាញវិជ្ជាជីវៈ។

ជំនាញទាំងនោះរួមមាន៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការធ្វើទីផ្សារជំនួញ និងបច្ចេកទេស ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យ។



# ស្ត្រីនៅប្រទេសកម្ពុជា

Water SHED
Water, Sanitation & Hygiene Enterprise Development




**អង្គការវ៉តធើសេដ** បានរកឃើញថាការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យទីផ្សារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ មិនមានភាពស្មើគ្នាបើប្រៀបធៀបទៅនឹងបុរស។

តាមទិន្នន័យបានបង្ហាញថា គម្រោងរួមគ្នាធ្វើការបានធ្វើឲ្យមានការចាប់អារម្មណ៍ពីស្ត្រីច្រើន នៅក្នុងសកម្មភាពស្វែងរកប្រាក់ចំណូលលើវិស័យការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

ទោះបីជាយ៉ាងណា ការចាប់អារម្មណ៍នោះមិនគ្រប់គ្រាន់ក្នុងការនាំឲ្យពួកគាត់ចូលរួម ឬពេញចិត្តការងារក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គួរឲ្យកត់សម្គាល់នោះទេ។



# គោលបំណងនៃការស្រាវជ្រាវ

១. កំណត់ ពីបុគ្គលិកលក្ខណៈរបស់ស្ត្រី ដែលអាចព្យាករណ៍ពីស្ថានភាពការងារបច្ចុប្បន្នក្នុងការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ការបន្តការងារនេះ និងការពេញចិត្តនឹងសកម្មភាពការងារបង្កើតប្រាក់ចំណូលលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

២. កំណត់ ថាតើ**កម្មករសំណង់** និង**អ្នកថែទាំសុខភាពសហគមន៍** មានបុគ្គលិកលក្ខណៈសាកសមជាមួយនឹងធ្វើការងារនេះដែរ ឬអត់

៣.ស្វែងយល់ពីចំណង់ចំណូលចិត្ត និងការសម្រេចចិត្តរបស់ស្ត្រី ថាតើសកម្មភាពបង្កើតប្រាក់ចំណូល រវាងនៅក្នុង និងក្រៅវិស័យការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ពួកគាត់នឹងចូលរួមមួយណា




# វិធីសាស្ត្រស្រាវជ្រាវ



**ស្ត្រី ១៥២នាក់ (៧០%)**

ស្ត្រីក្នុងគម្រោងរួមគ្នាធ្វើការ



**ស្ត្រី ៣៧នាក់ (១៧%)**

ស្ត្រីកម្មករសំណង់ដែលមិនបាន
ចូលរួមក្នុងគម្រោងរួមគ្នាធ្វើការ



**ស្ត្រី ២៩នាក់(១៣%)**

អ្នកថែទាំសុខភាពសហគមន៍ដែលមិន
បានចូលរួមក្នុងគម្រោងរួមគ្នាធ្វើការ

# រចនាបទនៃការសិក្សាស្រាវជ្រាវ




Water
SHED
Water, Sanitation & Hygiene Enterprise Development

# លទ្ធផលគុណវិស័យ

# សកម្មភាពបង្កើតប្រាក់ចំណូលពី WASH និងការរួមចំណែករកប្រាក់ចំណូលដល់ក្រុមគ្រួសារ

តួលេខ២១៖ កម្រិតនៃការរួមចំណែករកប្រាក់ចំណូលដល់គ្រួសារ ដោយការចូលរួមក្នុងសកម្មភាពដើម្បីប្រាក់ចំណូលពី WASH




**ភាគច្រើន(៧៦%) នៃស្ត្រីដែលចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ** បានរាយការណ៍ថាពួកគាត់ **បានរួមចំណែកក្នុងការរកប្រាក់ចំណូល** ស្មើនឹង ឬច្រើនជាងសមាជិកក្នុងគ្រួសាររបស់ពួកគាត់។

# បុគ្គលិកលក្ខណៈរបស់ស្ត្រីក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ស្ត្រីភាគច្រើនមិនបានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលក្នុងវិស័យការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនោះទេ។ ស្ត្រីដែលបានចូលរួមក្នុងសកម្មភាពនេះមានអារម្មណ៍ថា៖

- ពួកគាត់ ត្រូវការពិភាក្សាជាមួយស្វាមី មុននឹងធ្វើការសម្រេចចិត្តណាមួយទាក់ទងនឹងការងាររបស់គាត់
- ពួកគាត់ ត្រូវការផ្តល់ហេតុផលសមរម្យដល់គ្រួសាររបស់ពួកគាត់ មុននឹងពួកគាត់ទៅធ្វើការងារឆ្ងាយពីផ្ទះ

# ការចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលក្នុងវិស័យទឹកស្អាត និងអនាម័យ

ស្ត្រីនឹងចូលរួមច្រើនក្នុងសកម្មភាពបង្កើតប្រាក់ចំណូលពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រសិនបើ៖

- ពួកគាត់មានចំណេះដឹង លើបច្ចេកទេសផ្នែកផ្គត់ផ្គង់បង្គន់
- ប្រសិនបើពួកគាត់អាចស្រមៃថា កំពុងតែលក់បង្គន់





# ការរក្សាស្ត្រីឲ្យបន្តការងារក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ស្ត្រីភាគច្រើនចង់បន្តធ្វើការងារក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រសិនបើពួកគាត់៖

- មានគ្រួសារដែលជួយការងារផ្ទះ
- មានចំណេះដឹង លើបច្ចេកទេសគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់បង្គន់
- អាចឲ្យពួកគាត់ស្រមៃថា កំពុងលក់បង្គន់

# ការពេញចិត្តលើសកម្មភាពបង្កើតប្រាក់ចំណូល ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

**តាមការស្ទង់មតិបានបង្ហាញថា ស្ត្រីទាំងអស់**ពេញចិត្ត
នឹងការងាររបស់ពួកគាត់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត
និងអនាម័យជនបទ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏គ្មាន
ស្ត្រីណាម្នាក់នៅក្នុងវិស័យទឹកស្អាត អនាម័យ ចង់ធ្វើ
ការក្នុងទីផ្សារទឹកស្អាត សុខភាព អនាម័យ នោះដែរ។



# ការប្រៀបធៀបប្រវត្តិរូបរបស់ស្ត្រីក្នុងវិស័យទឹកស្អាត និងអនាម័យជនបទ ជាមួយអ្នកថែទាំសុខភាពសហគមន៍ និងកម្មករសំណង់

តាមការសិក្សាស្រាវជ្រាវរបស់ **អង្គការវ៉តែធើសេដ** បានបង្ហាញថាអ្នកថែទាំសុខភាពសហគមន៍ មិនមែនជាក្រុមគោលដៅ **របស់គម្រោង**បង្កើតប្រាក់ចំណូលក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនោះទេ។

ប៉ុន្តែ កម្មករសំណង់ គឺសាកសមជាងសម្រាប់ចូលរួមក្នុងគម្រោង សកម្មភាពបង្កើនប្រាក់ចំណូលក្នុងវិស័យទឹកស្អាត សុខភាព អនាម័យ។






# លទ្ធផលបរិមាណវិស័យ



# ការគាំទ្រពីគ្រួសារ និងភារកិច្ចនៅផ្ទះ

ទាំងស្ត្រីដែលបានចូលរួម និងមិនបានចូលរួមក្នុងគម្រោង បានលើកឡើងថា មុននឹងពួកគាត់ជ្រើសរើសការងារអ្វីមួយ ត្រូវពិចារណាទៅលើ **“ការងារដែលនៅផ្ទះ”** **“ការងារត្រូវធ្វើដំណើរ”** និង **”ការងារដែលជួយពីគ្រួសារ”**

WaterSHED

Water, Sanitation & Hygiene Enterprise Development

*"[ខ្ញុំអាច]ធ្វើការនៅផ្ទះពីព្រោះវាពិបាកក្នុងការធ្វើដំណើរឆ្ងាយ....។ ខ្ញុំ[គឺ]ទទួលខុសត្រូវមើលថែទាំក្រុមគ្រួសាររបស់ខ្ញុំ ដូច្នេះប្រសិនបើខ្ញុំធ្វើការឆ្ងាយពីផ្ទះ តើមាននរណាជាអ្នកថែទាំកូន[របស់]ខ្ញុំ? លើសពីនេះទៀត មិនត្រឹមតែអាចមើលថែទាំកូនរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំអាចធ្វើការនៅផ្ទះបានដែរ"*

(អ្នកលក់រាយផលិតផលទឹកស្អាត សុខភាព អនាម័យ ដែលជាក្រុមស្ត្រីដែលចូលរួមក្នុងគម្រោងរួមគ្នាធ្វើការ)


ចំនួនប្រាក់ចំណូល និងស្ថេរភាពនៃ
ប្រាក់ចំណូល
ស្ត្រីទាំងអស់ដែលជាក្រុមគោលដៅរបស់គម្រោង បានបង្ហាញពីសារៈសំខាន់នៃការរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសាររបស់គាត់។ ហើយពួកគាត់មួយចំនួនកំពុងពិចារណាលើចំនួនប្រាក់ចំណូល ដែលរកបានពីការងារជាក់លាក់ និងការងារផ្សេងទៀត។

*“ខ្ញុំមិនមានអ្វីទាំងអស់ ដូច្នេះខ្ញុំមានតែធ្វើជាកម្មករសំណង់ដែលអាចរកបានប្រាក់ចំណូលរៀងរាល់៦ថ្ងៃ ក្នុង១អាទិត្យ[...] ប្រសិនបើខ្ញុំលក់នំ ជួនកាលនំនៅសល់លក់មិនដាច់ ប៉ុន្តែប្រសិនបើខ្ញុំធ្វើការងារនេះ [កម្មករសំណង់] ខ្ញុំនឹងទទួលបានប្រាក់ចំណូលរៀងរាល់៦ថ្ងៃ*

(កម្មករសំណង់ដែលមិនបានចូលជាសមាជិកក្នុងគម្រោងរួមគ្នាធ្វើការ)


សមត្ថភាពរាងកាយ
និងថាមពល
អ្នកដែលយើងបានសម្ភាស៍ បានលើក
ឡើងថា ការងារដែលប្រើកម្លាំង គឺជា
"ការងារធ្ងន់ៗ" និង "អស់កម្លាំង"។ ដូច្នេះ
ជាស្ត្រីមិនអាចធ្វើការងារធ្ងន់ៗ បានទេ
នៅពេលដែលពួកគាត់ចាស់ទៅ។

*“ជាស្ត្រី ខ្ញុំមិនមាន [កម្លាំងកាយមាំមួន] ទេ តែប្តីរបស់ខ្ញុំ[...] តែងតែចេញទៅធ្វើការនៅខាងក្រៅ [ដូច្នេះ] មានតែខ្ញុំនៅផ្ទះម្នាក់ឯង [...] ។ [ការងារ] ដែលប្រើកម្លាំងតិចតួច គឺងាយស្រួលសម្រាប់ [ខ្ញុំ] ទោះបីជាការងារនោះរកបានប្រាក់ចំណូល [ចំនួន] តិចតួច [...]  ពីព្រោះខ្ញុំនៅតែអាចគ្រប់គ្រង [ការងារនោះ] បានទោះបីជា [ខ្ញុំ] មានកម្លាំងខ្សោយក៏ដោយ។*

(អ្នកថែទាំសុខភាពសហគមន៍ ដែលជាស្ត្រីមិនបានចូលរួមក្នុងគម្រោងរួមគ្នាធ្វើការ)


Water SHED
Water, Sanitation & Hygiene Enterprise Development
ការរួមចំណែកក្នុងសហគមន៍
ស្ត្រីបានបង្ហាញពីការចង់បានរបស់ពួកគាត់ នៅក្នុងការកាត់បន្ថយភាពក្រីក្រ ឬ
ធ្វើឲ្យប្រសើរឡើងនូវសុខភាព ក្នុងសហគមន៍ តាមរយៈការងាររបស់ពួកគាត់។

*[ការដែលធ្វើឲ្យប្រជាពលរដ្ឋមានសុខភាពល្អពិតជា] មានសារៈសំខាន់[…] ពីព្រោះ [ខ្ញុំ] ចង់ជួយកុមារឲ្យមានសុខភាពល្អ និងជួយឪពុកម្តាយរបស់ពួកគេក្នុងការកាត់បន្ថយភាពក្រីក្រ [ក្នុងគ្រួសាររបស់ពួកគេ]*

( អ្នកថែទាំសុខភាពសហគន៍ ដែលជាស្ត្រីដែលមិនបានចូលរួមគម្រោងរួមគ្នាធ្វើការ )




# ការពិភាក្សា និងអនុសាសន៍

# ការងារផ្តត់ផ្គង់ទឹកស្អាត និងអនាម័យជនបទបានផ្តល់ឱកាសឲ្យស្រ្តីមានភាពបត់បែន និងមានសេរីភាពផ្ទាល់ខ្លួន ក្នុង**ការបង្កើតប្រាក់ចំណូល** និង**ការងារផ្ទះ**

# អនុសាសន៍ទី១



រៀបចំការងារនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក៏ជាដំណោះស្រាយសម្រាប់អ្នកដែលត្រូវការតុល្យភាពប្រាក់ឈ្នួលការងារពីវិស័យនេះ និងកិច្ចការក្នុងគ្រួសារ

Water SHED
Water, Sanitation & Hygiene Enterprise Development



# អនុសាសន៍ទី២

សកម្មភាពរបស់កម្មវិធីកាត់ដេរកើតឡើង មិនមែនសម្រាប់តែចំពោះស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់គ្រួសាររបស់ពួកគាត់ផងដែរ



# អនុសាសន៍ទី៣

ដាក់បញ្ចូលវគ្គបណ្ដុះបណ្ដាល ការអប់រំ ភាពជាអ្នកដឹកនាំ ទៅក្នុងសកម្មភាព របស់កម្មវិធី ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការងារទាក់ទងនឹងការសម្រេចចិត្ត

# អនុសាសន៍ទី ៤



ត្រូវប្រាកដថា ស្ត្រីដែលជាក្រុមគោលដៅមានសិទ្ធិប្រើប្រាស់ធនធានពេលបានចូលរួម និងបន្តការងារក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ



# អនុសាសន៍ទី៥

ស្ត្រីដែលជាកម្មករសំណង់ គួរតែជាក្រុមគោលដៅ ដើម្បីចូលរួមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

# គោលដៅឆ្ពោះទៅមុខ




តើយើងអាចបញ្ជៀបវិស័យយេនឌ័រ ទៅក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធទឹកស្អាត និងអនាម័យជនបទបានដោយរបៀបណាខ្លះ?

Water SHED
Water, Sanitation & Hygiene Enterprise Development

# សូមអរគុណ!



